ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 11 / 2014
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**ជូនចំពោះ:** គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងសៀវភៅកំណត់ហេតុប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 2-TCCP-296

1. អង្គជំនុំជម្រះសាលាដំបូង បានទទួលសំណើមួយ ពីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំដាក់សៀវភៅកំណត់ហេតុប្រចាំថ្ងៃមួយ ដែលសរសេរដោយដើមបណ្តឹងរដ្ឋប្បវេណី មានរហស្សនាម 2-TCCP-296 ចូលទៅក្នុងសំណុំរឿង និងសុំឱ្យអង្គជំនុំជម្រះទទួលយកសៀវភៅកំណត់ហេតុនេះ ធ្វើជាភស្តុតាង អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា សៀវភៅកំណត់ហេតុប្រចាំថ្ងៃនេះកត់ត្រាអំពីរបបកម្ពុជាប្រជាធិបតេយ្យ ការរស់នៅ និងការធ្វើការងារនៅតាមសហករណ៍មួយចំនួនក្នុងស្រុកត្រាំកក់ទាំងមូល ព្រមទាំងសកម្មភាព និងការយល់ឃើញរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងគំនូរផងដែរ (ឯកសារ E323 កថាខណ្ឌ ៦)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា សៀវ

សៀវភៅកំណត់ហេតុប្រចាំថ្ងៃនេះគឺជាប្រភពឯកសារដើមសម្រាប់សៀវភៅមួយក្បាល ដែលមាននៅក្នុងសំណុំរឿងរួចហើយ ដែលមាននៅក្នុងឯកសារ D22/3248 (ឯកសារ E323 កថាខណ្ឌ ៦)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកទឡ្ហីករណ៍ថា សំណើរបស់ខ្លួនបានដាក់ទាន់ពេលវេលា សៀវភៅកំណត់ហេតុប្រចាំថ្ងៃនេះមានការពាក់ព័ន្ធ*ជាបឋម* អាចជឿជាក់បាន និងមានយថាភាព ហើយថា ការទទួលយកសៀវភៅកំណត់ហេតុប្រចាំថ្ងៃនេះផ្តល់ផលប្រយោជន៍យុត្តិធម៌ (ឯកសារ E323 កថាខណ្ឌ ៩-១៤)។ មិនមានភាគីណាមួយដាក់ចម្លើយតបទៅនឹងសំណើនេះឡើយ។

2. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភ័ស្តុតាងថ្មីនានា ដែលអង្គជំនុំជម្រះចាត់ទុកថាអាចនាំទៅដល់ការបញ្ជាក់ការពិត នៅពេលដែលភ័ស្តុតាងនោះបំពេញតាមបទដ្ឋាន *ការបញ្ជាក់បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវដោយវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ភ័ស្តុតាងដែលខ្លួនស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ មិនអាចរកបាននៅមុនពេលបើកសវនាការ ឬមិនអាចត្រូវបានរកឃើញកាលពីមុននេះ ដោយការយកចិត្តទុកដាក់ត្រឹមត្រូវ។

3. ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះសាលាដំបូងទទួលយកភ័ស្តុតាងដែលមិនបានបំពេញលក្ខខណ្ឌនេះបានច្បាស់លាស់ផងដែរ នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ (ឯកសារ E190 កថាខណ្ឌ ១៩-២១, ឯកសារ E289/2 កថាខណ្ឌ ៣)។ ករណីទាំងនេះរួមមានករណីដែលភ័ស្តុតាងទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងសម្ភារៈ ដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា នៅពេលដែលភ័ស្តុតាងដែលបានស្នើសុំដាក់នេះជាភ័ស្តុតាងដោះបន្ទុក និងត្រូវការវាយតម្លៃដើម្បីបញ្ចៀសភាពមិនយុត្តិធម៌ ឬនៅពេលដែលភាគីដទៃទៀតមិនបានជំទាស់ទៅនឹងភ័ស្តុតាងនេះ (*សូមមើល ឧទាហរណ៍* ឯកសារ E190 និងឯកសារ E172/24/5/1)។

4. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលស្គាល់ថា សំណើនេះមិនស្របទៅនឹងបទដ្ឋាននៃការបំពេញការងារដោយយកចិត្តទុកដាក់ ដែលមានចែងនៅក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងឡើយ ដោយសារតែសៀវភៅដែលផ្អែកទៅលើសៀវភៅកំណត់ហេតុប្រចាំថ្ងៃនោះ មាន "នៅក្នុងសំណុំរឿងជាយូរមកហើយ" (ឯកសារ E323 កថាខណ្ឌ ១១)។ ទោះបីជាយ៉ាងណាក៏ដោយ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើរបស់ខ្លួនជាច្រើនសប្តាហ៍ មុនពេលការចូលមកបង្ហាញខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីតាមការរំពឹងទុក ដែលផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យភាគីផ្សេងៗទៀតដើម្បីត្រៀមរៀបចំ

សម្រាប់ការសួរដេញដោល ដោយផ្អែកទៅលើសៀវភៅកំណត់ហេតុប្រចាំថ្ងៃនេះ។ លើសពីនេះទៀត ដោយសារតែសៀវភៅកំណត់ហេតុប្រចាំថ្ងៃនេះ គឺជាប្រភពនៃឯកសារ D22/3248 សៀវភៅកំណត់ហេតុនេះត្រូវបានសរសេរឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យអំពីព្រឹត្តិការណ៍នានា ដែលបានពិពណ៌នានៅក្នុងឯកសារ D22/3248 ហើយអាចមានព័ត៌មានពាក់ព័ន្ធដែលមិនមាននៅក្នុងឯកសារនេះទេ ដូច្នេះសៀវភៅកំណត់ហេតុប្រចាំថ្ងៃនេះនឹងមានសារៈប្រយោជន៍ចំពោះការបញ្ជាក់ការពិត។ លើសពីនេះទៀត មិនមានភាគីណាមួយជំទាស់ទៅនឹងការដាក់បញ្ចូលសៀវភៅកំណត់ហេតុប្រចាំថ្ងៃនេះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការដាក់បញ្ចូលសៀវភៅកំណត់ហេតុប្រចាំថ្ងៃនេះទៅក្នុងសំណុំរឿង និងការទទួលយកសៀវភៅកំណត់ហេតុប្រចាំថ្ងៃនេះជាភស្តុតាង គឺជាផលប្រយោជន៍យុត្តិធម៌។

5. នេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E323។